# រឿងទី៣៖ កាអ៊ីន និងអេបិល

**ខគម្ពីរ៖ ម៉ាថាយ១៩:១៤**

ប្រសិនបើអ្នកប្រព្រឹត្តល្អ អ្នកនឹងបានរីករាយឡើងវិញជាមិនខាន ផ្ទុយទៅវិញ បើអ្នកមិនប្រព្រឹត្តល្អទេ បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកឲ្យធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ»។

អដាំ និងអេវ៉ាដែលព្រះជាម្ចាស់បានបង្កើតមកនោះ ពួកគេបានបង្កើតកូនប្រុសពីរនាក់។

កូនច្បងឈ្មោះ«កាអ៊ីន» កូនប្អូនឈ្មោះ«អេបិល»។ កូនទាំងពីរបានធំធាត់ពីមួយថ្ងៃទៅមួយថ្ងៃ។

កាអ៊ីនជាបង ប្រកបរបរធ្វើស្រែចម្ការ។ ចំណែកអេបិលជាប្អូនវិញ ប្រកបរបរជាគង្វាលចៀម។

លុះដល់ពេលប្រមូលផល អេបិលជាប្អូនបាននាំយកកូនសត្វដែលកើតមុនគេបង្អស់ក្នុងហ្វូងសត្វរបស់គាត់ ព្រមទាំងខ្លាញ់របស់វាមកថ្វាយជាយញ្ញបូជាដល់ព្រះជាម្ចាស់។

កាអ៊ីនជាបង ក៏បានយកភោគផលពីស្រែចម្ការរបស់គាត់មកថ្វាយជាយញ្ញបូជាដល់ព្រះជាម្ចាស់ដែរ។

ប៉ុន្តែព្រះជាម្ចាស់ទទួលយកតែតង្វាយរបស់អេបិលទេ តង្វាយរបស់កាអ៊ីនទ្រង់ទុកចោលនៅទីនោះដដែល។

កាអ៊ីនមានការខឹងក្រោធជាខ្លាំង រហូតសម្រេចថានឹងសម្លាប់អេបិលជាប្អូនថែមទៀត។

ការអាក់អន់ចិត្តជាមួយព្រះជាម្ចាស់ និងចិត្តច្រណែនអេបិលជាប្អូនបានគ្រប់ដណ្ដប់ពេញក្នុងចិត្តរបស់កាអ៊ីន។

មានថ្ងៃមួយ មិនដឹងថាមានរឿងអ្វីទេ គ្មានអ្នកណាឃើញអេបិលសោះ។ ព្រះជាម្ចាស់បានសួរទៅកាអ៊ីនថា៖ «កាអ៊ីនអើយ តើអេបិលប្អូនឯងនៅឯណា?

កាអ៊ីនបានតបទៅព្រះជាម្ចាស់ថា៖ «ព្រះអង្គអើយ! តើធ្វើដូចម្ដេចដឹងថាប្អូនទូលបង្គំនៅឯណាទៅ? តើទូលបង្គំជាអ្នកឃ្វាលប្អូនទូលបង្គំឬ?»

ព្រះជាម្ចាស់ទ្រង់ជ្រាបគ្រប់អ្វីទាំងអស់ ពីរឿងដែលកាអ៊ីនបានសម្លាប់អេបិលជាប្អូននោះ។

ព្រះជាម្ចាស់ទ្រង់ជ្រាបគ្រប់អ្វីទាំងអស់ ហើយទ្រង់ធ្វើជាសួរទៅកាអ៊ីន ប៉ុន្តែកាអ៊ីនបានកុហកព្រះជាម្ចាស់។ ព្រះជាម្ចាស់បានដាក់ទោសកាអ៊ីន។

ទោះបីជាកាអ៊ីនជាមនុស្សមានបាបក៏ពិតមែន ប៉ុន្តែព្រះជាម្ចាស់នៅតែមានព្រះហឫទ័យអាណិតដល់កាអ៊ីន

ទ្រង់បានសន្យាជាមួយកាអ៊ីនថានឹងមិនឱ្យអ្នកណាម្នាក់សម្លាប់គាត់ឡើយ។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើអដាំ និងអេវ៉ា មានកូនប្រុសប៉ុន្មាននាក់? ហើយពួកគេមានឈ្មោះអ្វី?

b. តើកូនប្រុសរបស់អដាំ និងអេវ៉ាមានមុខរបរអ្វី?

c. តើកាអ៊ីន និងអេបិលថ្វាយដង្វាយអ្វីដល់ព្រះជាម្ចាស់?

d. សូមអានលោកុប្បត្តិ៤៖១១-១៦ រួចឆ្លើយសំណួរ។ តើព្រះជាម្ចាស់បានដាក់ទោសកាអ៊ីនដូចម្ដេច?



- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ៤៖៧)

> ប្រសិនបើអ្នកប្រព្រឹត្តល្អ អ្នកនឹងបានរីករាយឡើងវិញជាមិនខាន ផ្ទុយទៅវិញ បើអ្នកមិនប្រព្រឹត្តល្អទេ បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកឲ្យធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ៕។

## សកម្មភាពទី២

ការស្វែងរកពាក្យ៖ សូមស្វែងរកពាក្យនៅក្នុងក្រឡោនខាងក្រោម។

អេបិល, អដាំ, កាអ៊ីន, ការដាក់ទោស, កូនក្មេង, ព្រះជាម្ចាស់, បោកប្រាស់,  សេចក្ដីខ្មាស, អេវ៉ា, ផលផ្លែ, បងប្អូន, បងប្រុស, ប្អូន, តង្វាយ, សត្វចៀម, កំហឹង,

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បង | ប្អូន | រួម | ជំ | នឿ | គាំ | ទ្រ | គោះ | ស្លាប់ |
| ប្រុស | ភ្នំ | សុខ | នុំ | នី | កំ | ហឹង | ទ្វារ | ដល់ |
| ឈើ | ព្រៃ | សត្វ | ចៀម | ថា | ញាន | ការ | ដាក់ | ទោស |
| ខ្លីម | ការ | ដាក់ | ទោស | បេ | ថ្លៃ | ហិម | ផល | ផ្លែ |
| សារ | បោក | វ៉ា | កង | អង្គ | តួរ | សេច | ក្ដី | ខ្មាស |
| មេ | ប្រាស់ | អេ | បិល | កា | អ៊ីន | ធ្វើ | កូន | ពៅ |
| រៀន | គម្ពីរ | វិ | ន័យ | តង្វាយ | លាង | បាប | ក្មេង | យំ |
| ព្រះ | ជា | ម្ចាស់ | របស់ | ខ្ញុំ | អ | ដាំ | ដំ | ណាំ |

